## ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
## អភិបូជាព្រះអម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ
## ភ្នំពេញថ្មី ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩
## ព្រះនាងម៉ារីជាមនុស្សធម្មតាដែលភ្ជាប់ជាមួយព្រះជាម្ចាស់

**អត្ថបទទី១៖ វិវរណៈ ១១,១៩ក;១២,១-៦ក.១០ក**

ពេលនោះ មានទីសម្គាល់មួយយ៉ាងធំលេចចេញមក នៅលើមេឃ គឺមានស្ត្រីមួយរូបស្លៀកពាក់ព្រះអាទិត្យបិទបាំងកាយ មានព្រះច័ន្ទនៅក្រោមជើង ព្រមទាំងមានពាក់ផ្កាយដប់ពីរជាមកុដនៅលើក្បាលផង។ វវ ១២,១

**អត្ថបទទី២៖ កូរិនថូសទី១ ១៥,២០-២៧ក**

សត្រូវចុងក្រោយបង្អស់ ដែលនឹងត្រូវរំលាយចោលនោះ គឺសេចក្តីស្លាប់។ ១ករ ១៥,២៦

**ដំណឹងល្អ៖ លូកា ១,៣៩-៥៦**

តើរូបខ្ញុំនេះមានឋានៈអ្វី បានជាមាតាព្រះអម្ចាស់របស់ខ្ញុំ មកសួរសុខទុក្ខខ្ញុំដូច្នេះ? លក ១,៤៣

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងគោរពព្រះនាងម៉ារីដែលបានចូលនៅក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់មុនគេបង្អស់ ព្រះនាងម៉ារីដែលមានជីវិតដ៏រុងរឿងទាំងរូបកាយទាំងវិញ្ញាណ នៅក្នុងព្រះជាម្ចាស់មុនគេបង្អស់។ ពីដើមរៀងមក គ្រីស្តបរិស័ទស្រឡាញ់ព្រះនាងម៉ារីនៅគ្រប់ទីកន្លែង ដោយសារគេបានឃើញព្រះនាងម៉ារីជាគ្រីស្តបរិស័ទមួយរូបធម្មតា ដែលភ្ជាប់ជាមួយព្រះជាម្ចាស់នៅក្នុងរបៀបពិសេសបំផុត។ ណែនាំឲ្យយើងជាគ្រីស្តបរិស័ទមានកម្លាំង ដោយសារយើងនឹកឃើញទោះបីយើងជាមនុស្សធម្មតាក៏យើងអាចភ្ជាប់ជាមួយព្រះជាម្ចាស់ ដើម្បីពោរពេញដោយអំណរសប្បាយនិងសេចក្តីសុខសាន្ត។ ព្រះនាងម៉ារី បានណែនាំឲ្យយើងមើលឃើញវត្តមានរបស់ព្រះជាម្ចាស់យ៉ាងជាក់ស្តែង ប្រសិនបើយើងបើកភ្នែកយើងអាចមើលឃើញវត្តមានរបស់ព្រះជាម្ចាស់គ្រប់ទីកន្លែង។

ពេលយើងមើលឃើញទេសភាពយ៉ាងស្អាត ដូចនៅជើងភ្នំដែលខ្ពស់ជាងគេនៅបារាំង យើងនឹកឃើញវត្តមានព្រះជាម្ចាស់ ដោយសារមានតែព្រះជាម្ចាស់ដែលបានបង្កើតទាំងភ្នំ ទាំងផ្កា ទាំងអ្វីៗទាំងអស់។ មានព្រះវិហារតូចមួយ មានឈើឆ្កាង មានរូបព្រះនាងម៉ារី ធ្វើឲ្យយើងនឹកឃើញវត្តមានរបស់ព្រះជាម្ចាស់ណែនាំឲ្យយើងពោរពេញដោយសេចក្តីសុខសាន្ត។ វត្តមានរបស់ព្រះនាងម៉ារី ណែនាំឲ្យយើងនឹកឃើញវត្តមានរបស់ព្រះជាម្ចាស់ ឲ្យយើងសួរខ្លួនឯងថា **តើខ្ញុំធ្វើដូចម្តេចដើម្បីភ្ជាប់ជាមួយព្រះជាម្ចាស់ដូចព្រះនាងម៉ារី? តើអនាគតរបស់ខ្ញុំទៅណា?** ថ្ងៃនេះ ព្រះជាម្ចាស់បានណែនាំឲ្យព្រះនាងម៉ារីទៅស្ថានបរមសុខតែម្តង ព្រះជាម្ចាស់សង្គ្រោះព្រះនាងម៉ារីនិង

សង្គ្រោះយើងទាំងអស់ទាំងវិញ្ញាណទាំងរូបកាយ។ ព្រះនាងម៉ារីក៏មានទុក្ខលំបាកដែរ នៅពេលព្រះនាងឃើញកូនរបស់ខ្លួនសោយទិវង្គតព្រះនាងឈឺចិត្តណាស់ ព្រះនាងម៉ារីក៏ចេះហាត់ដៃប៉ុន្តែនៅពេលគាត់ទៅដល់ផ្ទះយាយអេលីសាប៉ែតហើយ ភ្លាមនោះគាត់ច្រៀងកោតសរសើរព្រះជាម្ចាស់អស់ពីដួងចិត្ត ដោយសារព្រះនាងម៉ារីបានយកព្រះជាម្ចាស់អាទិភាពរបស់ព្រះនាង ជាទីពឹងរបស់ព្រះនាងតែម្តង។ ជាមូលហេតុ ព្រះនាងម៉ារីបានចូលស្ថានបរមសុខទាំងរូបកាយទាំងវិញ្ញាណ មានជីវិតថ្មីដ៏រុងរឿងរួមជាមួយព្រះជាម្ចាស់ ដោយសារព្រះនាងម៉ារីបានឆ្លើយតបជាមួយព្រះជាម្ចាស់។

សម្រាប់ជីវិតរបស់យើង **តើព្រះជាម្ចាស់មានគម្រោងការអ្វីខ្លះ? តើយើងធ្វើដូចម្តេច ដើម្បីឆ្លើយតបគម្រោងការរបស់ព្រះជាម្ចាស់ដែលមានសម្រាប់យើង?** ឲ្យយើងធ្វើរស់នៅនៅក្នុងជីវិតប្រចាំថ្ងៃធម្មតារបស់យើង ដោយរស់នៅក្នុងរបៀបអស្ចារ្យព្រោះយើងបានភ្ជាប់ជាមួយព្រះជាម្ចាស់។ ព្រះនាងម៉ារីជាមនុស្សធម្មតា ប៉ុន្តែគាត់រស់នៅក្នុងរបៀបអស្ចារ្យដោយសារគាត់បានភ្ជាប់ជាមួយព្រះជាម្ចាស់ជានិច្ច ដោយរស់នៅក្នុងដង្ហើម រស់នៅក្នុងបរិយាកាសរបស់ព្រះជាម្ចាស់។ ដូច្នេះ ឲ្យយើងបើកភ្នែកដើម្បីរៀបចំខ្លួនសម្រាប់ជីវិតអស់កល្បជានិច្ច ពីមួយថ្ងៃទៅមួយថ្ងៃដូចព្រះនាងម៉ារីយើងរៀបចំខ្លួនដោយព្រះជាម្ចាស់គង់នៅជាមួយយើង និងធ្វើដំណើរជាមួយយើងដើម្បីឲ្យយើងទៅមុខតទៅទៀត។

ថ្ងៃនេះ យើងអរព្រះគុណព្រះអង្គដែលបានប្រទានព្រះនាងម៉ារីដើម្បីធ្វើដំណើរជាមួយយើង ណែនាំយើងឲ្យបន្តិចម្តងៗយើងអាចចូលនៅក្នុងព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ផ្ទាល់។ ព្រះនាងម៉ារីនៅក្នុងព្រះហឫទ័យព្រះជាម្ចាស់ហើយ ប៉ុន្តែព្រះនាងក៏នៅលើផែនដីនេះដើម្បីចាប់ដៃយើង ទាក់ទាញយើងឲ្យយើងមានកម្លាំងតទៅមុខទៀត។ រួមជាមួយព្រះនាងម៉ារីយើងកោតសរសើរព្រះជាម្ចាស់ដែលបានស្រឡាញ់យើង ដែលបានជ្រើសរើសយើង ដែលណែនាំឲ្យយើងទទួលជីវិតដ៏បរិបូរណ៍ជាប្រចាំថ្ងៃ។ អាម៉ែន៕